# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

គណៈឱសថការីកម្ពុជា
ក្រុមប្រឹក្សាគណៈឱសថការីជាតិ
លេខៈ ០៣៧/១៦ កឱជ

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនាឆ្នាំ២០១៦

## ប្រធានក្រុមប្រឹក្សាគណៈឱសថការីជាតិ

ជំម្រាបជូន

## ប្រធានក្រុមប្រឹក្សាគណៈឱសថការីភូមិភាគ ១

**កម្មវត្ថុៈ** បន្តដោះស្រាយនូវបញ្ហាឱសថការីដែលកំពុងទទួលខុសត្រូវបច្ចេកទេសតាមឱសថស្ថាននៅរាជធានីភ្នំពេញដែលមិនបានចុះឈ្មោះចូលជាសមាជិកគណៈឱសថការីកម្ពុជា ។

**យោង ៖**
- ព្រះរាជក្រឹត្យ ស្តីពី ការបង្កើតគណៈឱសថការីកម្ពុជា
- ច្បាប់ ស្តីពី ច្បាប់វិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងឱសថ
- របាយការណ៍ប្រជុំនៅថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០១៦
- របាយការណ៍ប្រជុំនៅថ្ងៃទី ៧ ខែមិថុនា ឆ្នាំ២០១៦

តបតាមកម្មវត្ថុ និងយោងខាងលើប្រធានក្រុមប្រឹក្សាគណៈឱសថការីជាតិ សូមជម្រាបជូនលោកប្រធានក្រុមប្រឹក្សាគណៈឱសថការីភូមិភាគ១ ជ្រាបថាៈ តាមការស្រាវជ្រាវកន្លងមករបស់ក្រុមប្រឹក្សាគណៈឱសថការីជាតិ បានរកឃើញនូវឱសថការីមួយចំនួនបានបើកឱសថស្ថាននៅតាមបណ្តាខណ្ឌមួយចំនួនក្នុងរាជធានីភ្នំពេញដោយមិនបានចុះឈ្មោះចូលជាសមាជិកគណៈឱសថការីកម្ពុជា ។ ដូច្នេះដើម្បីពង្រឹងផ្នែកវិន័យ និងភាពថ្លៃថ្នូររបស់ឱសថការីកម្ពុជា ។ ក្រុមប្រឹក្សាគណៈឱសថការីជាតិ ស្នើឲ្យលោកប្រធាន ធ្វើការស្រាវជ្រាវបន្តទៀតនូវបញ្ហាខាងលើនេះឲ្យបានសមស្រប ហើយប្រកបដោយតម្លាភាព ដោយមិនឲ្យលើសពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៦ ។ ប្រសិនបើក្រុមប្រឹក្សាគណៈឱសថការីភូមិភាគ១ អសកម្មក្នុងការស្រាវជ្រាវ ក្រុមប្រឹក្សាគណៈឱសថការីជាតិ និងធ្វើការស្រាវជ្រាវបន្តទៀត ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានក្រុមប្រឹក្សាគណៈឱសថការីភូមិភាគ១ ជួយសម្រួល និងដោះស្រាយបញ្ហាទាំងអស់នេះជាបន្ទាន់ ។

សូមលោកប្រធានទទួលយកនូវការរាប់អានអំពីខ្ញុំ ។

ឱសថបណ្ឌិត. ហេង_ប៊ុនគៀត

**ចម្លងជូន ៖**

- មន្ទីរសុខាភិបាលរាជធានីភ្នំពេញ
- ក្រុមប្រឹក្សាគណៈឱសថការីភូមិភាគ ១
- ក្រុមប្រឹក្សារាជធានី-ខេត្តទាំង ២៥
- ឯកសារ-កាលប្បវត្តិ